# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 04-Jul-2016, 15:22
CMS/CFO: Sann Rada

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៦

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

**ការជំទាស់របស់មេធាវីការពារក្ដីលោក ខៀវ សំផន ទៅនឹងការទទួលយកសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្ដី ស្ដីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ (ឯកសារ E418)**

---

<u>ដាក់ដោយ</u>៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

**ជំនួយការ៖**

លោកស្រី សេង សុជាតា

<u>ដាក់ជូន</u>៖

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យូរ ឧត្ដារា

ចៅក្រម Claudia FENZ

ចៅក្រម យ៉ា សុខន

| | |
|---|---|
| កញ្ញា Marie CAPOTORTO | **សហព្រះរាជអាជ្ញា៖** |
| កញ្ញា Soumeya MEDJEBEUR | លោកស្រី ជា លាង |
| លោក Clément BOSSIS | លោក Nicholas KOUMJIAN |
| កញ្ញា Cécile ROUBEIX | |
| កញ្ញា អ៊ុំច ស្រីផាត | **មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់** |
| លោក តាន់ ឆាយរ័ត្ន | |
| | **មេធាវីការពារក្តីលោក នួន ជា** |

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

១. នៅថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៦ ភាគីបានទទួលការជូនដំណឹងអំពីសំណើរបស់ក្រុមសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ សុំអញ្ញាតពីអង្គជំនុំជម្រះសាលាដំបូង (“អង្គជំនុំជម្រះ”) ដើម្បីដាក់សារណា របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ស្តីពី “អាពាហ៍ពិពាហ៍ដោយបង្ខំ” (“សំណើ”)[1]។

២. មេធាវីការពារក្តីលោក ខៀវ សំផន (“មេធាវីការពារក្តី”) សូមជំទាស់ ដោយហេតុថាសំណើនេះ មិនអាចទទួលយកបាន។

## I- **<u>ច្បាប់ជាធរមាន</u>**

៣. អង្គជំនុំជម្រះនានានៃតុលាការនេះ បានកំណត់ដូចគ្នានូវលក្ខណៈវិនិច្ឆ័យនៃការទទួលយកសារណា របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ដោយផ្អែកលើវិធាន ៣៣ នៃវិធានផ្ទៃក្នុង[2]។

៤. បើតាមអង្គជំនុំជម្រះតុលាការកំពូល៖

*“តួនាទីចម្បងរបស់អ្នកដែលមិនមែនភាគីនៃរឿងក្តីនៅក្នុងបញ្ហាច្បាប់ព្រហ្មទណ្ឌអន្តរជាតិ គឺជាការជួយដល់តុលាការនៅក្នុងការសម្រេចលើរឿងក្តីណាមួយ ជាពិសេស លើបញ្ហាច្បាប់ដែលពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន ដែល<u>មានខ្លឹមសារបន្ថែមឲ្យបានគ្រប់គ្រាន់ទៅលើទឡ្ហីករណ៍នានាដែលបានទទួលពីភាគីនៃរឿងក្តីរួចហើយ</u>”*[3]។

---

[1] សំណើសុំការអនុញ្ញាតដាក់សារណាស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំ ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E418** (“សំណើ”)។

[2] យោងតាមវិធាន ៣៣ នៃវិធានផ្ទៃក្នុង “នៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធី បើយល់ថាចាំបាច់ដើម្បីវិនិច្ឆ័យទោសឲ្យបានត្រឹមត្រូវសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះអាចអញ្ជើញ ឬផ្តល់ឱកាសឲ្យអង្គការ ឬបុគ្គលណាមួយដាក់ជូននូវសារណាជាលាយលក្ខណ៍អក្សរ ពាក់ព័ន្ធទៅនឹងបញ្ហាណាមួយក៏បាន”។

[3] សេចក្តីសម្រេចលើសំណើសុំធ្វើអន្តរាគមន៍ ឬសុំដាក់សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្តី នៅក្នុងកិច្ចដំណើរការនីតិវិធី

*"សម្រាប់ការបំពេញមុខនាទីរបស់អ្នកមិនមែនជាភាគីនៃរឿងក្តីក្នុងការជួយដល់តុលាការ គឺនៅតែចាំបាច់ត្រង់ថា បំណងរបស់បុគ្គល ឬស្ថាប័នក្នុងការដាក់សារណារបស់ខ្លួន គឺដើម្បីមូលហេតុផលប្រយោជន៍អរូបីលើបញ្ហាជាក់លាក់ណាមួយជាជាងក្នុងន័យជំរុញ ឬបង្កើតឲ្យមានលទ្ធផលជាក់លាក់ណាមួយទាក់ទងនឹងករណីព្រហ្មទណ្ឌ (...)។ បន្ថែមលើនេះទៀត សារណារបស់បុគ្គល ឬស្ថាប័ននានា ដែលមានផលប្រយោជន៍អរូបីនៅក្នុងបញ្ហាដែលត្រូវយកមកវិនិច្ឆ័យនោះ អាចត្រូវបានទទួលយកដោយស្របច្បាប់ ដរាបណាសារណាទាំងនោះត្រូវបានចាត់ទុកថាចាំបាច់ដើម្បីវិនិច្ឆ័យទោសឲ្យបានត្រឹមត្រូវទៅលើរឿងក្តី"*[4]។

*"បញ្ហាដែលត្រូវពិចារណាជាបឋមក្នុងការទទួលឋានៈជាអ្នកមិនមែនជាភាគីនៃរឿងក្តី គឺថាតើតុលាការនឹងទទួលបានផលប្រយោជន៍នៅក្នុងការវិនិច្ឆ័យរឿងក្តីនេះដែរឬយ៉ាងណា"*[5]។

៥. ជាអាទិ៍ អង្គជំនុំជម្រះបាន "លើកឡើងថាអ្នកដែលមិនមែនជាភាគីនៃរឿងក្តីគឺជាអ្នកប្រឹក្សាឯករាជ្យ និងអព្យាក្រឹត្យរបស់តុលាការ ដែលមានតួនាទីគ្រាន់តែជូនព័ត៌មាន ពុំមែនការពារក្តីនោះឡើយ"[6]។

## II- ភាពមិនអាចទទួលយកបាននៃសំណើ

៦. យោងតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ច្បាស់ដោយយុត្តិសាស្ត្ររបស់តុលាការ សំណើនេះមិនអាចទទួលយកបាន ដោយសារហេតុផលជាច្រើន៖ ១) សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីមិនមានភាពពាក់ព័ន្ធ ដើម្បីជួយឲ្យអង្គជំនុំជម្រះសម្រេចលើបញ្ហាវិវាទ ២) សំណើនេះ

---

លើបណ្តឹងសាទុក្ខ ក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **F20/1** កថាខណ្ឌ ៨ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[4] ដូចយោងលើ កថាខណ្ឌ ៩ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[5] ដូចយោងលើ កថាខណ្ឌ ១១។

[6] សេចក្តីសម្រេចលើសំណើសុំអនុញ្ញាតដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ឬចូលរួមធ្វើអន្តរាគមន៍លើភាពអាចទទួលយកបាន និងការប្រើប្រាស់ភស្តុតាងដែលទទួលបានតាមរយៈទារុណកម្ម ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E350/7** ("អនុស្សរណៈ **E350/7**") កថាខណ្ឌ ៥ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

បង្កើបឲ្យឃើញស្រពិចស្រពិលពីការតស៊ូមតិ ដើម្បីធ្វើឲ្យការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្លាយជាបទឧក្រិដ្ឋ ៣) សំណើនេះធ្វើឡើងនាប់ពេក ពីព្រោះភាគីនៃរឿងក្តីមិនទាន់បានដាក់ទឡ្ហីករណ៍របស់ខ្លួនផង។

៧. ទីមួយ ការវិភាគដែលបានធ្វើឡើងខ្វះភាពពាក់ព័ន្ធដើម្បីជួយឲ្យអង្គជំនុំជម្រះសម្រេចលើបញ្ហាដែលខ្លួនត្រូវដោះស្រាយ។ ជាក់ស្តែង ការវិភាគគតិយុត្តិបានលើកឡើងអំពីស្ថានភាពបច្ចុប្បន្ននៃនីតិទំនៀមទម្លាប់អន្តរជាតិ។ ម្ចាស់សំណើរៀបរាប់អំពីបម្រែបម្រួលខាងយុត្តិសាស្ត្រថ្មីៗនេះ ហើយបញ្ជាក់ថាខ្លួននឹងវិភាគលម្អិតលើ "សេចក្តីសម្រេចជាមូលដ្ឋានទាំងឡាយ ទស្សនៈផ្ទុយ និងបង្ហាញទឡ្ហីករណ៍ ដែលនាំឲ្យមានការសន្មតអំពីការឯកភាពទទួលស្គាល់ជាអន្តរជាតិនេះ"[7]។ ទឡ្ហីករណ៍បែបនេះគ្មានប្រយោជន៍អ្វីដល់អង្គជំនុំជម្រះ ដែលត្រូវសម្រេចលើស្ថានភាពច្បាប់នៅសម័យកាលនៃអង្គហេតុ គឺមិនមែនលើបញ្ហាចង់ដឹងថាតើស្ថានភាពច្បាប់សព្វថ្ងៃនេះយ៉ាងដូចម្តេចនោះទេ។

៨. ម្ចាស់សំណើស្នើផ្តល់ការវិភាគប្រៀបធៀបស៊ីជម្រៅ និងប្លែកខុសគេ ដែលបញ្ជាក់អំពីភាពជំនាញរបស់ពួកគេ តាមរយៈការចុះទៅស្រាវជ្រាវដល់ទីកន្លែងកាលពីពេលថ្មីៗកន្លងទៅនេះ ដោយរួមបញ្ចូលទាំងការសម្ភាសន៍ជាមួយជនរងគ្រោះនៃអាពាហ៍ពិពាហ៍ដោយបង្ខំ នៅប្រទេសជាច្រើននៃទ្វីបអាហ្វ្រិក[8]។ ក៏ប៉ុន្តែ គ្មានម្ចាស់សំណើណាម្នាក់បង្ហាញអំពីបទពិសោធន៍ ឬការយល់ដឹងអំពីករណីនៅកម្ពុជាឡើយ ជាពិសេស នៅសម័យកាលនៃយុត្តាធិការលើពេលវេលារបស់តុលាការ។ លទ្ធផលស្រាវជ្រាវថ្មីៗនេះអំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ នៅប្រទេសនានានៃទ្វីបអាហ្វ្រិកមិនមែនជាភ័ស្តុតាងប្រៀបធៀបពាក់ព័ន្ធនោះទេ ពីព្រោះថាវាខុសគ្នាទាំងពេលវេលា ភូមិសាស្ត្រ និងវប្បធម៌ ពីអង្គហេតុដែលអង្គជំនុំជម្រះត្រូវកាត់សេចក្តី។ ក្នុងន័យនេះ សក្ខីកម្មរបស់អ្នកជំនាញ

---

[7] សំណើ កថាខណ្ឌ ១៥។ សូមមើលផងដែរ៖ កថាខណ្ឌ ១១ "អ្នកដាក់ពាក្យសុំសូមអះអាងថា សារណានេះអាចជួយអង្គជំនុំជម្រះសាលាដំបូងក្នុងការសម្រេចអំពីការកំណត់បទចោទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងទម្រង់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ <u>នៅពេលដែលយុត្តិសាស្ត្រអន្តរជាតិលើបញ្ហានេះមានបម្រែបម្រួលក្នុងអំឡុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ</u>" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម) និងកថាខណ្ឌ ១៣ "អ្នកដាក់ពាក្យសុំផ្តល់ជំនាញដ៏ពិសេស [...] នៅខណៈពេលមួយដែលទ្រឹស្តីនៃការចោទប្រកាន់ និងយុត្តិសាស្ត្រស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងទម្រង់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ <u>កំពុងរីងមាំ</u>" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[8] សំណើ កថាខណ្ឌ ១, ២, ៧, ៩, ១០, ១៣។

ពីររូបដែលត្រូវបានកោះហៅឲ្យមកផ្តល់សក្ខីកម្ម[9] នឹងអាចផ្តល់ភ័ស្តុតាងមានភាពពាក់ព័ន្ធ និងមានប្រយោជន៍ច្រើនជាងដល់អង្គជំនុំជម្រះ។

៩. ទីពីរ ការអានសំណើនេះបង្ហាញថា ផលប្រយោជន៍របស់ម្ចាស់សំណើលើសពីផលប្រយោជន៍បញ្ញាសាមញ្ញ ដែលតម្រូវដោយយុត្តិសាស្ត្ររបស់តុលាការ។ សំណើរបស់ពួកគេហាក់ដូចជាចង់ចូលរួមចំណែកក្នុងការអភិវឌ្ឍការទទួលស្គាល់អាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងនីតិព្រហ្មទណ្ឌអន្តរជាតិ ទៅវិញទេ។ ជាក់ស្តែង ការអះអាងថា សារណារបស់ពួកគេនឹងបង្ហាញនូវការវិភាគ "អំពីហេតុអ្វីបានជាអាពាហ៍ពិពាហ៍ដោយបង្ខំ [...] គួរត្រូវបានកំណត់ជាបទឧក្រិដ្ឋ"[10] ដោយផ្គួបផ្គានឹងការខិតជិតរបស់ម្ចាស់សំណើជាមួយជនរងគ្រោះនៃអាពាហ៍ពិពាហ៍ដោយបង្ខំ បង្ហាញអំពីលក្ខណៈតស៊ូមតិនៃសំណើនេះ។ ថ្វីត្បិតតែការតស៊ូមតិដើម្បីធ្វើឲ្យការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្លាយជាបទឧក្រិដ្ឋពិតជាគួរឲ្យកោតសរសើរ ប៉ុន្តែ វាមិនមានប្រយោជន៍អ្វីដល់អង្គជំនុំជម្រះ ក្នុងការសម្រេចលើបញ្ហាដែលខ្លួនត្រូវកាត់សេចក្តីនោះទេ។

១០. ទីបី សំណើនេះធ្វើឡើងឆាប់ពេក ពីព្រោះថាសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីត្រូវ *"មានខ្លឹមសារបន្ថែមឲ្យបានគ្រប់គ្រាន់ទៅលើទឡ្ហីករណ៍នានា ដែលបានទទួលពីភាគីនៃរឿងក្តីរួចហើយ"*[11]។ ក៏ប៉ុន្តែ ទឡ្ហីករណ៍របស់ភាគីស្តីពីការរៀបអាពាហ៍ពិពាហ៍នឹងត្រូវដាក់ នៅពេលធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល។ រហូតមកទល់នឹងពេលនេះ អង្គជំនុំជម្រះតែងតែគិតថាខ្លួនមានទឡ្ហីករណ៍គ្រប់គ្រាន់ដែលផ្តល់ដោយភាគីនៃរឿងក្តី ដោយមិនចាំបាច់មានអន្តរាគមន៍ពីតតិយជន ដើម្បីជួយឲ្យអង្គជំនុំជម្រះសម្រេចលើបញ្ហាវិវាទទាំងនេះ[12]។ ដូច្នេះ គ្មានហេតុផលអ្វីដែលអង្គជំនុំជម្រះត្រូវការអន្តរាគមន៍ពីតតិយជន ដើម្បីសម្រេចលើបញ្ហាអាពាហ៍ពិពាហ៍នោះទេ។

---

[9] អ៊ីមែលរបស់លោក Ken ROBERTS មានចំណងជើងថា "បញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ស្តីពីការចាត់ចែងលើការរៀបអាពាហ៍ពិពាហ៍" ផ្ញើថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង ១៣ និង ៥១ នាទី។

[10] សំណើ កថាខណ្ឌ ១៧ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[11] សូមមើលខាងលើ កថាខណ្ឌ ៤ និងកំណត់សម្គាល់ជើងទំព័រលេខ ៣។

[12] អនុស្សរណៈ **E350/7** កថាខណ្ឌ ៥ (ត្រង់កថាខណ្ឌ ៤ នៃអនុស្សរណៈនេះ អង្គជំនុំជម្រះផ្តល់ឧទាហរណ៍ខ្លះៗអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះផ្សេងទៀត ដែលមានអត្ថន័យដូចគ្នា)។

១១. ជាចុងក្រោយ អង្គជំនុំជម្រះគ្មានប្រយោជន៍អ្វីត្រូវទទួលយកសារណានោះ ដើម្បីសម្រេចលើបញ្ហានៃការរៀបអាពាហ៍ពិពាហ៍ ដែលខ្លួនត្រូវកាត់សេចក្តីនោះទេ។

១២. **<u>អាស្រ័យហេតុនេះ</u>** មេធាវីការពារក្តីស្នើសុំអង្គជំនុំជម្រះមេត្តា**បដិសេធ**សំណើនេះ។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br><br>មេធាវី Anta GUISSÉ | រាជធានីភ្នំពេញ<br><br>ទីក្រុងប៉ារីស | |